# អដ្ឋកថា កច្ចបជាតក

ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធអ្នករួចអំពីអហិវាតរោគម្នាក់ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **ជនិតំ មេ ភវិតំ មេ** ដូច្នេះជាដើម ។

មានរឿងតំណាលថា នៅក្នុងនគរសាវត្ថី បានកើតអហិវាតរោគឡើងក្នុងត្រកូលមួយ មាតាបិតាក៏ប្រាប់ថា នែកូនសម្លាញ់ កូនកុំនៅក្នុងផ្ទះនេះឡើយ ចូរទម្លាយជញ្ជាំងគេចទៅកាន់ទីណាមួយរក្សាជីវិតទុកចុះ ពេលក្រោយសឹមត្រឡប់មក ហើយគាស់យកកំណប់ទ្រព្យដែលមាតាបិតាកប់នៅទីនេះ រក្សាទ្រព្យទុកចិញ្ចឹមជីវិតឲ្យជាសុខចុះ ។ បុត្តនោះទទួលពាក្យរបស់មាតាបិតាហើយ ទម្លាយជញ្ជាំងគេចខ្លួនទៅ កាលរោគរបស់ខ្លួនជាសះស្បើយហើយ ទើបត្រឡប់មកគាស់យកទ្រព្យដែលកប់ទុកនោះ នៅគ្រប់គ្រងផ្ទះយ៉ាងសុខសាន្ត ។ ថ្ងៃមួយ បុត្តនោះ ឲ្យមនុស្សកាន់ទឹកដោះថ្លា ប្រេង សំពត់ និងគ្រឿងស្លៀកដណ្ដប់ជាដើម ទៅកាន់វត្តជេតពន ថ្វាយបង្គំព្រះសាស្តាហើយអង្គុយក្នុងទីដ៏សមគួរមួយ ។ ព្រះបរមសាស្តា ទ្រង់ធ្វើបដិសណ្ឋារៈជាមួយនឹងបុរសនោះ ហើយត្រាស់សួរថា ម្នាលអ្នកដ៏ចម្រើន បានឮថា អហិវាតរោគកើតឡើងក្នុងផ្ទះរបស់អ្នក អ្នកធ្វើដូចម្ដេច ទើបរួចខ្លួនបាន ?

បុរសនោះ បានក្រាបបង្គំទូលរឿងរ៉ាវនោះឲ្យទ្រង់ជ្រាប ។

ព្រះសាស្តាត្រាស់ថា ម្នាលឧបាសក សូម្បីកាលពីមុន ជនទាំងឡាយណា កាលភ័យកើតឡើងហើយ ធ្វើសេចក្តីអាល័យជាប់ចំពាក់នឹងលំនៅរបស់ខ្លួន មិនព្រមទៅកាន់ទីដទៃ ជនទាំងនោះក៏ដល់នូវការអស់ជីវិត ប៉ុន្តែជនទាំងឡាយណា មិនអាឡោះអាល័យ មិនជាប់ចំពាក់ នឹងទីជាលំនៅរបស់ខ្លួន គេចទៅកាន់ទីដទៃ ជនទាំងនោះ រួចផុតអំពីសេចក្តីស្លាប់ ហើយទ្រង់នាំយករឿងក្នុងអតីតមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះមហាសត្វបដិសន្ធិក្នុងត្រកូលស្មូនឆ្នាំង នៅក្នុងភូមិមួយធ្វើឆ្នាំងលក់ចិញ្ចឹមបុត្តភរិយា ។ ក្នុងកាលនោះ នៅជិតនគរពារាណសីមានស្រះធំមួយ ជាប់តនឹងស្ទឹងធំ ស្រះនោះមានទឹកហូរទៅដល់ស្ទឹងក្នុងពេលទឹកច្រើន ។ កាលទឹកតិចក៏ដាច់ចេញអំពីគ្នា ត្រីនិងអណ្តើកតែងដឹងថា ឆ្នាំនេះភ្លៀងល្អ ឆ្នាំនេះភ្លៀងមិនល្អ ។ ក្រោយមក ត្រីនិងអណ្តើកដែលកើតក្នុងស្រះនោះ ដឹងថា ឆ្នាំនេះភ្លៀងនឹងរាំង លុះដល់វេលាទឹកហូរជាប់តគ្នា ទើបនាំគ្នាចាកចេញអំពីស្រះទៅកាន់ស្ទឹង ប៉ុន្តែអណ្តើកមួយមិនព្រមទៅដោយគិតថា **ឥទំ មេ ជាតដ្ឋានំ វុឌ្ឍិតដ្ឋានំ មាតាបិតូហិ វសិតដ្ឋានំ, ន សក្កោមិ ឥទំ ជហិតុំ** ទីនេះជាទីកើតរបស់អញ អញចម្រើនហើយនៅទីនេះ ជាទីដែលម៉ែឪរបស់អញធ្លាប់រស់

ទៅ អញមិនអាចនឹងលះបង់ទីនេះ ទៅណាបានទេ ។ លុះដល់រដូវប្រាំងស្ងួត ទឹកគោកអស់ អណ្តើកនោះក៏កាយដីចូលទៅនៅក្នុងកន្លែងដែលជាទីគាស់ដីរបស់ព្រះមហាសត្វ ។ ព្រះមហាសត្វបានទៅកាន់ទីនោះ ដោយបំណងថានឹងយកដី ទើបយកចបធំកាប់ដី កាប់ត្រូវអណ្តើកហើយយកចបគាស់ឡើងដូចដុំដី បោះប្រមៀលទៅលើគោក ។ អណ្តើកនោះ ទទួលទុក្ខវេទនាយ៉ាងខ្លាំង រួចពោលរៀបរាប់ថា អញមិនអាចលះបង់លំនៅបាន ទើបដល់នូវសេចក្តីវិនាសយ៉ាងនេះ ហើយពោលគាថាទាំងនេះថា

ជនិតំ មេ ភវិតំ មេ ឥតិ បង្កេ អវស្សយឹ
តំ មំ បង្កោ អជ្ឈភវិ យថា ទុព្វលកំ តថា
តំ តំ វទាមិ ភគ្គវ សុណោហិ វចនំ មម ។

ខ្ញុំនៅក្នុងភក់ដោយគិតថា ខ្ញុំកើតហើយ ខ្ញុំចម្រើនហើយ (ក្នុងទីនេះ) ភក់បានកប់សង្កត់ខ្ញុំនោះ ធ្វើឲ្យទុព្វលភាព បពិត្រភគ្គវៈ ខ្ញុំសូមពោលនូវហេតុនោះនឹងអ្នក អ្នកចូរស្តាប់នូវពាក្យខ្ញុំចុះ ។

គាមេ វា យទិ វា រញ្ញេ សុខំ យត្រាធិគច្ឆតិ
តំ ជនិតំ ភវិតញ្ច បុរិសស្ស បជានតោ
យម្ហិ ជីវេ តម្ហិ គច្ឆេ ន និកេតហតោ សិយា ។

បុគ្គលបានសេចក្ដីសុខក្នុងទីណា ទោះក្នុងស្រុក ឬក្នុងព្រៃ ទីនោះហើយ ជាទីកើតជាទីចម្រើន របស់បុរសជាអ្នកដឹង ( នូវប្រយោជន៍និងមិនមែនប្រយោជន៍ ) បុគ្គលគប្បីរស់នៅក្នុងទីណា គប្បីទៅក្នុងទីនោះចុះ កុំគប្បីឲ្យទីដែលធ្លាប់នៅ សម្លាប់ខ្លួនបានឡើយ ។

បណ្ដាបទទាំងនោះ បទថា ជនិតំ មេ ភវិតំ មេ បានដល់ ទីនេះ ជាទីកើតរបស់ខ្ញុំ ជាទីចម្រើនរបស់ខ្ញុំ ។

បទថា ឥតិ បង្កេ អវស្សយឹ សេចក្ដីថា ខ្ញុំដេកអាល័យ គឺសម្រេចការរស់នៅក្នុងភក់នេះ ដោយហេតុនេះ ។

បទថា អជ្ឈភវិ បានដល់ គ្របសង្កត់ គឺឲ្យដល់នូវសេចក្ដីវិនាស ។ (អណ្ដើកនោះ) ហៅស្ទូនផ្ទាំងថា ភគ្គវៈ ភគ្គវៈនេះជាបញ្ញត្តិនាមនិងគោត្តរបស់ស្ទូនផ្ទាំង ។

បទថា សុខំ បានដល់ សេចក្ដីសុខផ្លូវកាយនិងផ្លូវចិត្ត ។

បទថា តំ ជនិតំ ភវិតញ្ច បានដល់ នោះជាទីកើតនិងជាទីចម្រើនឡើង ។

បទថា បជានតោ បានដល់ អ្នកដឹងប្រយោជន៍និងមិនមែនប្រយោជន៍ គឺហេតុនិងមិនមែនហេតុ ។

បទថា ន និកេតហតោ សិយា បានដល់ ធ្វើសេចក្ដីអាល័យ

ក្នុងលំនៅហើយមិនទៅកាន់ទីដទៃ ត្រូវលំនៅសម្លាប់ ។ មិនគួរឲ្យដល់មរណទុក្ខដូច្នេះឡើយ ។

អណ្តើកនោះ កាលពោលនឹងព្រះពោធិសត្វយ៉ាងនេះហើយ ក៏អស់ជីវិតទៅ ។ ព្រះពោធិសត្វរើសយកអណ្តើកទៅ ហើយឲ្យអ្នកស្រុកមកប្រជុំគ្នា កាលនឹងទូន្មានមនុស្សទាំងឡាយ ទើបពោលយ៉ាងនេះថា

អ្នកទាំងឡាយ ចូរមើលអណ្តើកនេះចុះ ពេលដែលត្រីនិងអណ្តើកដទៃៗ ទៅកាន់ស្ទឹងធំ អណ្តើកនេះមិនអាចកាត់សេចក្តីអាល័យក្នុងទីជាលំនៅរបស់ខ្លួនបាន មិនទៅជាមួយនឹងសត្វទាំងនោះ អណ្តើកនេះទៅដេកក្រោមដីដែលជាកន្លែងគាស់ដីរបស់ខ្ញុំ កាលខ្ញុំគាស់ដី បានយកចបធំគាស់ចំខ្នងរបស់វា ហើយបោះទៅលើគោកដូចដុំដី អណ្តើកនេះ បានបើកបង្ហាញនូវអំពើដែលខ្លួនធ្វើ ខ្សឹកខ្សួលដោយគាថាចំនួន ២ គាថា ហើយក៏អស់ជីវិតទៅ អណ្តើកមានសេចក្តីអាល័យនឹងលំនៅរបស់ខ្លួនដល់នូវការអស់ជីវិត សូម្បីអ្នកទាំងឡាយក៏កុំធ្វើដូចអណ្តើកនេះ តាំងអំពីនេះទៅ អ្នកទាំងឡាយកុំប្រកាន់ដោយអំណាចតណ្ហា ដោយអំណាចគ្រឿងឧបភោគនិងបរិភោគថា រូប សំឡេង ក្លិន រស ផោដ្ឋព្វៈជារបស់អញ បុត្តជារបស់អញ ធីតាជារបស់អញ ទាសីនិងទាសៈ មាស ប្រាក់ជារបស់អញឡើយ សត្វតែម្នាក់ប៉ុណ្ណោះ ត្រាច់រង្គាត់ទៅកាន់ភព ៣ ។ ព្រះពោធិសត្វបានឲ្យឱវាទដល់មហាជនដោយពុទ្ធលីលា ( របៀបដូច